# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 16-Feb-2015, 15:53
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងការជំទាស់របស់ ខៀវ សំផន ចំពោះការទទួលយកឯកសារដែលបានស្នើឡើងសម្រាប់សំណុំរឿង០០២/០២

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះសាលាដំបូង
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យ៉ា សុខន
ចៅក្រម Claudia FENZ
ចៅក្រម យូរ ឧត្តរា

**ចម្លងជូន:**
សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:
លោក ពេជ អង្គ
លោកស្រី Marie GUIRAUD

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**ចម្លងជូន:**
មេធាវីការពារក្ដីជនជាប់ចោទ:
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោកស្រី Anta GUISSÉ
លោក Arthur VERCKEN

សហចៅក្រមស៊ើបអង្កេត
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Mark B. HARMON

មេធាវីប្រចាំការ:
លោកស្រី ទូច វណ្ណៈរ័ក្ស
លោក Calvin SAUNDERS

## I. សេចក្ដីផ្ដើម

1. សហព្រះរាជអាជ្ញាសូមឆ្លើយតបទៅនឹងការជំទាស់របស់ ខៀវ សំផន អំពីការទទួលយកភស្តុតាងនានាដែលបានស្នើឡើងសម្រាប់សំណុំរឿង០០២/០២ នៅក្នុងសំណើរបស់ខ្លួនលេខ E327/3 ដាក់នៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៥ ហើយដែលបានជូនដំណឹងមកភាគីនៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥[1]។ មេធាវីការពារក្ដី ខៀវ សំផន ("មេធាវីការពារក្ដី") បានស្នើសូមឱ្យកត់សម្គាល់មួយ ដល់អង្គជំនុំជម្រះសាលាដំបូងឱ្យ (i)ច្រានចោលជាបន្ទាន់ចំពោះសំណើរបស់សហព្រះរាជអាជ្ញា ឯកសារលេខ E305/13/1 ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៤[2] និង (ii) ប្រកាសពីភាពមិនអាចទទួលយកបានចំពោះឯកសារទាំងឡាយដូចបានចុះបញ្ជីក្នុងឧបសម្ព័ន្ធ ក របស់ពួកគេ (E327/3.2) ដែលឯកសារទាំងនេះបានស្នើឡើងដោយសហព្រះរាជអាជ្ញានៅក្នុងឧបសម្ព័ន្ធ គ១ របស់ខ្លួន (ឯកសារក្នុងសំណុំរឿង ០០២, E305/13.22) និងឧបសម្ព័ន្ធ គ២ (ឯកសារមិនមែនក្នុងសំណុំរឿង០០២, E305/13.23)[3] នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤។

2. ជាការឆ្លើយតបនឹងការអះអាង និងការជំទាស់ទាំងនេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា៖ ក. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចរួចហើយថា បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា នៅក្នុងឯកសារ E305/13/1 គឺជាការកែសម្រួលមួយដែលអាចទទួលយកបានទៅលើបញ្ជីឆ្នាំ២០១១ ដែលវិធាន ៨៧(៤)នៃវិធានផ្ទៃក្នុង មិនអនុវត្តបាន ខ. ឯកសារទាំងអស់ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា ក្នុងឧបសម្ព័ន្ធ គ១ និង គ២ សុទ្ធតែពាក់ព័ន្ធ ដោយសារឯកសារទាំងនោះ គឺជាភស្តុតាងស្ថិតក្នុងវិសាលភាពនៃសំណុំរឿង០០២/០២ ដូចបានកំណត់ដោយសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លេខ E301/9/1.1 ហើយក៏មិនច្រំដែលនោះដែរ។

## II. អំណះអំណាង

### *ក. ឯកសារដែលបានចុះបញ្ជីដោយសហព្រះរាជអាជ្ញា ក្នុងឯកសារលេខ E305/13/1*

---

[1] **E327/3** Khieu Samphan's '*Exceptions d'irrecevabilité portant sur certains documents proposés pour le procès 002/02 et demande d'un véritable débat contradictoire sur la valeur probante*', ២ កុម្ភៈ ២០១៥, FR ERN 01059843-48 និង **E327/3.2** ឧបសម្ព័ន្ធ ក មានចំណងជើងថា '*Exceptions d'irrecevabilité relatives aux documents listés par les Co-Procureurs*', ត្រង់ ERN 01060735។

[2] **E327/3** កថាខណ្ឌ១៤-១៦ & កថាខណ្ឌ២៥។

[3] **E327/3** កថាខណ្ឌ២៥។

**(ឧបសម្ព័ន្ធ ឃ១, ឃ២ & ឃ៣)**

3. មេធាវីការពារក្តីតវ៉ាថា ឯកសារដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា ឯកសារ E305/13/1 ចុះកាលបរិច្ឆេទថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៤ មិនបានដាក់នៅចំពោះមុខអង្គជំនុំជម្រះដើម្បីលើកស្ទួយដល់សេចក្តីបង្គាប់របស់អង្គជំនុំជម្រះទេ[4] និងសន្និដ្ឋានថាវិធាន៨៧(៤)ត្រូវតែអនុវត្តចំពោះឯកសារទាំងនេះ[5]។ ជាការបន្ថែម ពួកគេអះអាងថា ការទទួលយកឯកសារទាំងនេះ គឺជាការជួយហួសហេតុចំពោះសហព្រះរាជអាជ្ញា ដែលនឹងធ្វើឱ្យខូចខាតដល់មេធាវីការពារក្តី និងថាសំណើរបស់សហព្រះរាជអាជ្ញា គួរបានបដិសេធចោលជាបន្ទាន់ ឬឯកសារដែលបានស្នើទាំងប៉ុន្មាន គួរបានចាត់ទុកថាមិនអាចទទួលយកបាន អនុលោមតាមវិធាន៨៧(៤) និង៨៧(៣) នៃវិធានផ្ទៃក្នុង[6]។

4. សហព្រះរាជអាជ្ញាសូមរំឭកថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសេចក្តីសម្រេចលើសំណើសុំរួមឱ្យសម្រេច*សាជាថ្មី* លើការអនុវត្តវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៤[7] ដែលកថាខណ្ឌទី១១នេះ សម្រេចថា "ឈរលើមូលដ្ឋាននៃការលើកលែង អង្គជំនុំជម្រះនឹងពិចារណាបញ្ជីឆ្នាំ២០១៤ ដែលបានដាក់អនុលោមតាមឯកសារលេខ E305 ថាជាការកែសម្រួលអាចទទួលយកបានចំពោះបញ្ជីឆ្នាំ២០១១ ដែលវិធាន៨៧(៤) នៃវិធានផ្ទៃក្នុងមិនអនុវត្តបាន"[8]។ ក្នុងកថាខណ្ឌ១២ អង្គជំនុំជម្រះសាលាដំបូង បានពិចារណាបន្ថែមទៀតថា "ដើម្បីផលប្រយោជន៍នៃសវនាការត្រឹមត្រូវយុត្តិធម៌ និងឆាប់រហ័ស ពេលនេះអង្គជំនុំជម្រះកំពុងតែពិចារណាថា បញ្ជីឯកសារចុះឆ្នាំ២០១៤របស់ភាគី ដែលបានដាក់ អនុលោមតាមឯកសារ E305 គឺជាការកែការសម្រួលអាចទទួលយកបានចំពោះបញ្ជីឯកសារចុះឆ្នាំ២០១១ ដែលវិធាន៨៧(៤) នៃវិធានផ្ទៃក្នុងមិនអនុវត្តបាន <u>ទោះបីបញ្ជីឯកសារទាំងនោះ បានដាក់នៅក្រោយការចាប់ផ្តើម</u>

---

[4] **E305** ដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងឱ្យដាក់សម្ភារៈដែលបានធ្វើបច្ចុប្បន្នភាព ដើម្បីរៀបចំសវនាការក្នុងសំណុំរឿង ០០២/០២, ដែលបានបំពេញបង្គ្រប់តាមរយៈឯកសារលេខ **E307/1** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពី "សេចក្តីសម្រេចលើសំណើរួមរបស់ភាគីសុំការបំភ្លឺអំពីការអនុវត្តវិធាន ៨៧(៤) (ឯកសារ E307) និងសេចក្តីជូនដំណឹងរបស់ក្រុមមេធាវីការពារក្តី នួន ជា ស្តីពីការមិនដាក់បញ្ជីភស្តុតាងដែលបានធ្វើបច្ចុប្បន្នភាព (ឯកសារ E305/3)។

[5] **E327/3** កថាខណ្ឌ១៤។

[6] **E327/3** កថាខណ្ឌ១៦។

[7] **E307/1/2** "សេក្តីសម្រេចលើសំណើសុំរួមឱ្យសម្រេចសាជាថ្មីលើការអនុវត្តវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង", ២១ តុលា ២០១៤។

[8] **E307/1/2** កថាខណ្ឌ១១។

សវនាការក៏ដោយ”[9]។ ដើម្បីឲ្យកាន់តែច្បាស់ អង្គជំនុំជម្រះសាលាដំបូងបានថ្លែងថា “អង្គជំនុំជម្រះសូមបញ្ជាក់ថា សំណើសុំដាក់ឯកសារថ្មីណាមួយ ឬសំណើសុំឲ្យស្តាប់សាក្សីថ្មីណាមួយ ក្នុងពេលអនាគត មានន័យថា ក្រោយថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៤ ត្រូវតែបំពេញទៅតាមលក្ខណតម្រូវនៃវិធាន៨៧(៤)”[10]។

5. នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា បញ្ជីឯកសារពាក់ព័ន្ធនឹងសំណុំរឿង០០២/០២ ស្នើឡើងដោយសហព្រះរាជអាជ្ញា (ឯកសារ E305/13 និង E305/13/1) ពិតជាបានដាក់ត្រឹមត្រូវឆ្លើយតបទៅនឹងដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលេខ E305[11] និងថាបើមានការជំទាស់ណាមួយ ត្រូវដាក់មិនឲ្យហួសពីថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៥ ឡើយ។ ហេតុដូច្នេះ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គ្រប់ឯកសារទាំងអស់ដែលបានចុះបញ្ជីក្នុងឧបសម្ព័ន្ធទាំងបីនៃសំណើសុំរបស់ កសព លេខ E305/13/1 ត្រូវបានពិចារណាថាបានដាក់យ៉ាងត្រឹមត្រូវតាមច្បាប់នៅចំពោះមុខអង្គជំនុំជម្រះ ដែលឧបសម្ព័ន្ធនោះរួមមាន ឧបសម្ព័ន្ធ ឃ១[12], ឧបសម្ព័ន្ធ ឃ២[13] និងឧបសម្ព័ន្ធ ឃ៣[14]។ មេធាវីការពារក្តីមិនបានបញ្ជូនអង្គហេតុ ឬកាលៈទេសៈថ្មីណាមួយដែលយុត្តិកម្មដើម្បីឲ្យអង្គជំនុំជម្រះសាលាដំបូង ពិចារណាឡើងវិញលើសេចក្តីសម្រេចរបស់ខ្លួនឡើយ។

6. ជាការបន្ថែម មេធាវីការពារក្តីខកខានក្នុងការបង្ហាញអំពីការជំទាស់ ទៅនឹងឯកសារលេខ E305/13/1 អនុលោមតាមវិធាន៨៧(៣) នៃវិធានផ្ទៃក្នុង។ ដូចបានគូសបញ្ជាក់ក្នុងឧបសម្ព័ន្ធ ឃ១, ឃ២ និងឃ៣ នៅត្រង់កន្លែងដែលនិយាយពី “សេចក្តីអធិប្បាយ” និង “ចំណុចនៃការចោទប្រកាន់” ដែលឯកសារទាំងនេះសុទ្ធតែពាក់ព័ន្ធនឹងសំណុំរឿង០០២/០២។ ក្រៅពីនេះ ភាគ

[9] **E307/1/2** កថាខណ្ឌ១២, សង្កត់ន័យត្រង់ឃ្លាមានគូសបន្ទាត់ពីក្រោម។

[10] **E307/1/2** កថាខណ្ឌ១២, សង្កត់ន័យត្រង់ឃ្លាមានគូសបន្ទាត់ពីក្រោម។

[11] **E327** ការកំណត់កាលបរិច្ឆេទរបស់អង្គជំនុំជម្រះសាលាដំបូង សម្រាប់សេចក្តីជំទាស់ទៅនឹងឯកសារផ្សេងៗទាក់ទងនឹងសំណុំរឿង០០២/០២”, ១១ ធ្នូ ២០១៤, កថាខណ្ឌ១។

[12] **E305/13/1.1 -** ឧបសម្ព័ន្ធ ឃ១ មានឯកសារចំនួន១៦ ដែលបានទទួលយកដាក់បញ្ចូលទៅក្នុងសំណុំរឿង០០២/០១ រួចហើយ ប៉ុន្តែមិនមាននៅក្នុងបញ្ជីឯកសាររបស់ កសព ចុះខែមេសា ឆ្នាំ២០១១ ទេ។

[13] **E305/13/1.2 -** ឧបសម្ព័ន្ធ ឃ២ មានឯកសារចំនួន១០១ ដែលបានដាក់បញ្ចូលរួចហើយទៅក្នុងសំណុំរឿង០០២។

[14] **E305/13/1.3 -** ឧបសម្ព័ន្ធ ឃ៣ មានឯកសារចំនួន២៦ មិនមានក្នុងសំណុំរឿង០០២។

ច្រើននៃឯកសារទាំងនេះ គឺជាសេចក្តីថ្លែង កំណត់ហេតុស្តាប់ចម្លើយ ឬជាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលអ្នកឆ្លើយទាំងនោះត្រូវបានសហព្រះរាជអាជ្ញាស្នើឲ្យធ្វើជាសាក្សី ឬជាដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះក្នុងសំណុំរឿង០០២/០២។ មានឯកសារខ្លះក្នុងចំណោមឯកសារទាំងនោះ បានដាក់នៅលើអ៊ិនធ័រហ្វេសរួចហើយ ដោយមេធាវីការពារក្តី ជាឯកសារដែលពួកគាត់មានបំណងប្រើប្រាស់ក្នុងអំឡុងសវនាការផ្តល់សក្ខីកម្ម នៅក្នុងសំណុំរឿង០០២/០២[15]។

## *ខ. ឯកសារដែលបានចុះបញ្ជីដោយសហព្រះរាជអាជ្ញា ក្នុងឯកសារលេខ E305/13 (ឧបសម្ព័ន្ធ គ១ និង គ២)*

7. មេធាវីការពារក្តីអះអាងថា ឯកសារមួយចំនួនធំដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញានៅក្នុងឯកសារលេខ E305/13 ដែលជាឯកសារពាក់ព័ន្ធនឹងអង្គហេតុស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០២ ទៅតាមនិយមន័យដែលបានកំណត់ក្នុងឯកសារលេខ E301/9/1.1 ក្នុងនោះគឺឯកសារចំនួន៥២ នៅក្នុងឧបសម្ព័ន្ធ គ១ (ពីឯកសារចំនួន៣៨៣ ក្នុងឯកសារលេខ E305/13.22) និងឯកសារចំនួន៣២ នៅក្នុងឧបសម្ព័ន្ធ គ២ (ពីឯកសារចំនួន៤៧៣ ក្នុងឯកសារលេខ E305/13.23[16])។ លើសពីនេះ មេធាវីការពារក្តីតវ៉ាថា ឯកសារផ្សេងទៀតដែលសហព្រះរាជអាជ្ញាបានស្នើឡើង គឺជាឯកសារដែលជាប់ពាក់ព័ន្ធជាចំបង ទៅនឹងអង្គហេតុដែលស្ថិតនៅក្រៅវិសាលភាពនៃ

---

[15] ឧទាហរណ៍ ទាក់ទងនឹងសក្ខីកម្មរបស់ សយ សែន (Say Sen) ដែលមេធាវីការពារក្តីបានចុះបញ្ជីឯកសារមួយដូចតទៅនេះនៅលើអ៊ិនធ័រហ្វេស: (ក) ឯកសារលេខ **E3/4846** (ឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា "បទសម្ភាសន៍ជាមួយ សយ សែន" ចុះបញ្ជីដោយមេធាវីការពារក្តីនៅលើអ៊ិនធ័រហ្វេសសម្រាប់សវនាការ ចុះថ្ងៃទី៥ ខែកុម្ភៈ ២០១៥, ត្រង់លេខ ២៧២-២៧៤។ ឯកសារដែលបង្ហាញនៅក្នុងឯកសារលេខ **E305/13/1.1**, ឧបសម្ព័ន្ធ ឃ១ របស់ កសព ត្រង់លេខ១៦)។ (ខ) **D22/1370** និង **D22 1370/1** (ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សយ សែន ដែលមេធាវីការពារក្តីបានចុះបញ្ជីនៅលើអ៊ិនធ័រហ្វេស សម្រាប់សវនាការនៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ត្រង់លេខ ២៩៦-២៩៨, ឯកសារដែលបង្ហាញនៅក្នុងឯកសារលេខ **E305/13/1.2**, ឧបសម្ព័ន្ធ ឃ២ របស់ កសព ត្រង់លេខ៣៦)។ (គ) **D22/1370.2** (អត្ថបទរបស់ DC-Cam មានចំណងជើងថា "អតីតអ្នកទោសក្រាំងតាចាន់" ដែលមេធាវីការពារក្តីបានចុះបញ្ជីនៅលើអ៊ិនធ័រហ្វេស សម្រាប់សវនាការនៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ត្រង់លេខ ២៩៦-២៩៨, ឯកសារដែលបង្ហាញនៅក្នុងឯកសារលេខ **E305/13/1.2**, ឧបសម្ព័ន្ធ ឃ២ របស់ កសព ត្រង់លេខ៨៩)។

[16] **E327/3** កថាខណ្ឌ១៩ និង **E327/3.2**, តែមួយទំព័រត្រង់ ERN ជាភាសាបារាំង 01060735។

សំណុំរឿង០០២/០២ និងថា ឯកសារមួយចំណែក ទំនងជាពាក់ព័ន្ធដែរ ឯកសារនោះអាចច្រំដែល (ឯកសារចំនួន១៥ នៅក្នុងឧបសម្ព័ន្ធ គ១ និងចំនួន៤៤ នៅក្នុងឧបសម្ព័ន្ធ គ២)[17]។

8. សហព្រះរាជអាជ្ញាសូមរំឭកថា សហព្រះរាជអាជ្ញាមានបន្ទុកក្នុងការបង្ហាញភ័ស្តុតាង ចំពោះពិរុទ្ធរបស់ជនជាប់ចោទ និងថាគ្រប់ភ័ស្តុតាងទាំងអស់អាចទទួលយកបាន អនុលោមតាមវិធាន៨៧(១) នៃវិធានផ្ទៃក្នុង លើកលែងតែចំពោះទឡ្ហីករណ៍ជាក់លាក់មួយចំនួនមានកំណត់ ដូចមានចែងនៅក្នុងវិធាន៨៧(៣) ដែលគេអាចច្រានចោលបាន។ សហព្រះរាជអាជ្ញាសូមបញ្ជាក់ថា ខៀវ សំផន មិនជំទាស់ទៅនឹងឯកសារណាមួយដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា តាមរយៈបញ្ជីឯកសាររបស់ខ្លួន ឆ្នាំ២០១១ ដែលបានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ទេ ជាពិសេសទាក់ទងនឹងឯកសារ១៥៤៦ ដែលគ្មានការគូសបញ្ជាក់ដោយពណ៌ក្នុងឧបសម្ព័ន្ធ ១ក ដល់ ២០ក[18]។ ជាការបន្ថែម គ្មានការជំទាស់នឹងឯកសារភាគច្រើនដែលបានស្នើឡើងក្នុងឧបសម្ព័ន្ធ គ១ និង គ២ ទេ មានន័យថា ឯកសារចំនួន៣១៦ ក្នុងឧបសម្ព័ន្ធ គ១ និង ៣៩៧ ក្នុងឧបសម្ព័ន្ធ គ២។ ការជំទាស់របស់មេធាវីការពារក្ដីផ្ដោតលើឯកសារចំនួន១៤៣ ដោយផ្អែកទៅលើតែភាពមិនពាក់ព័ន្ធ និងភាពច្រំដែល តាមវិធាន៨៧(៣)(ក)តែមួយប៉ុណ្ណោះ។ មេធាវីការពារក្ដី តាមពិតមិនបានអះអាងថា តើឯកសារណាមួយនៃឯកសារទាំង១៤៣នេះ មិនពាក់ព័ន្ធ ឬមិនត្រឹមត្រូវតាមយថាភូតឡើយ។ ដើម្បីគាំទ្រអំណះអំណាងរបស់ខ្លួនថា ឯកសារទាំង១៤៣ មិនពាក់ព័ន្ធ ឬច្រំដែល មេធាវីការពារក្ដីបានផ្ដល់តារាងចំណាត់ថ្នាក់ឯកសារតែមួយទំព័រ ដោយបានកំណត់អត្តសញ្ញាណតាមសេចក្ដីយោងនៃសំណុំរឿង០០២ របស់ខ្លួន ជាពីរប្រភេទថា៖ (i) ឯកសារដែលស្ថិតនៅក្រៅវិសាលភាពទាំងស្រុងនៃសំណុំរឿង០០២/០២ និង (ii) ឯកសារស្ថិតនៅក្រៅវិសាលភាពជាចំបងនៃសំណុំរឿង០០២/០២ និងបើមិនដូច្នោះទេ គឺជាឯកសារច្រំដែល[19]។

9. ការជំទាស់ទាំងនេះ មានភាពច្រពេចស្រពិលមិនអាចទទួលយកបាន ទាក់ទិននឹងភ័ស្តុតាងដែលបានជំទាស់ និងដំណោះស្រាយដែលបានស្នើឡើង ដោយសារគ្មានភាពជាក់លាក់ ឬសម្អាងហេតុគ្រប់គ្រាន់ដើម្បីបំពេញទៅតាមលក្ខខណ្ឌតម្រូវនៃវិធាន៨៧(៣)នៃវិធានផ្ទៃក្នុង សម្រាប់ការច្រានចោល

[17] **E327/3** កថាខណ្ឌ១៩ និង **E327/3.2**, តែមួយទំព័រត្រង់ ERN ជាភាសាបារាំង 01060735។

[18] **E305/13** បញ្ជីឈ្មោះឯកសារសម្រាប់សវនាការរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨០(៣), ១៣ មិថុនា ២០១៤។

[19] **E327/3.2** ឧបសម្ព័ន្ធ ក នៃឯកសាររបស់ ខៀវ សំផន មានចំណងជើងថា "Exception d'irrecevabilité relatives aux documents listés par les Co-Procureurs", តែមួយទំព័រត្រង់ ERN ជាភាសាបារាំង 01060735។

ភ័ស្តុតាង ដូច្នេះការជំទាស់ទាំងនេះគប្បីត្រូវបានបដិសេធចោល។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ជូនភាគីក្នុងសេចក្តីសម្រេចរបស់ខ្លួនលេខ E185.1, កថាខណ្ឌ៩(ច) ថា៖“ការជំទាស់លើឯកសារ ឬប្រភេទឯកសារជាក់លាក់ណាមួយ ដែលមិនមានភាពជាក់លាក់គ្រប់គ្រាន់អំពីមូលដ្ឋាននៃភាពមិនអាចទទួលយកបាន ដូចដែលខ្លួនបានចោទប្រកាន់ ត្រូវតែបដិសេធចោល”[20]។

10. ម្យ៉ាងវិញទៀត ចំពោះឯកសារចំនួន១៤៣ គឺជាឯកសារដែលពាក់ព័ន្ធយ៉ាងពិតប្រាកដតាម *តម្លៃបឋម* របស់វាទៅនឹងសំណុំរឿង០០២/០២ ដូចសហព្រះរាជអាជ្ញាបានគូសបញ្ជាក់ក្នុងឧបសម្ព័ន្ធ គ១ និងគ២ របស់ខ្លួន នៅត្រង់កន្លែងដែលមាននិយាយពី “សេចក្តីអធិប្បាយ” និង “ចំណុចនៃការចោទប្រកាន់”។ សហព្រះរាជអាជ្ញាសូមផ្តល់សេចក្តីលម្អិតបន្ថែមទៀតដូចខាងក្រោមនេះ ទាក់ទងនឹងភាពពាក់ព័ន្ធនៃឯកសារទាំង១៤៣ ដែលបានស្នើឡើងក្នុងឧបសម្ព័ន្ធ គ១ និង គ២។ សហព្រះរាជអាជ្ញាសូមរំឭកថា បន្ទុករបស់ភាគីដែលស្វែងរកការបង្ហាញភ័ស្តុតាង គឺគ្រាន់តែបង្ហាញឲ្យឃើញនូវភាពពាក់ព័ន្ធ(ភាពជឿជាក់បាន) ក្នុងកម្រិត*អប្បបរមា* ប៉ុណ្ណោះ។ មិនតម្រូវឲ្យសហព្រះរាជអាជ្ញាកំណត់ថា ភ័ស្តុតាងត្រូវតែមានតម្លៃភស្តុតាងខ្ពស់នោះឡើយ។ ជាការបន្ថែម សហព្រះរាជអាជ្ញាគូសបញ្ជាក់ថា ភ័ស្តុតាងនេះមិនច្រំដែលទេ ប៉ុន្តែជាភ័ស្តុតាងផ្ទាល់នៃឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តឡើង ឬជាភ័ស្តុតាងបមាណីករណ៍ទៅលើចំណែកផ្សេងទៀតនៃភ័ស្តុតាង។ ភ័ស្តុតាងបមាណីករណ៍ មានសារៈសំខាន់ជាពិសេសសម្រាប់សហព្រះរាជអាជ្ញា ក្នុងការបំពេញភារកិច្ចរបស់ខ្លួនក្នុងការបង្ហាញភ័ស្តុតាងនៃរឿងក្តី។

### *ក. ឧបសម្ព័ន្ធ គ១ - ឯកសារចំនួន៥២ ដែលចោទថាស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០២*

[20] **E185/1** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើការជំទាស់ទៅនឹងឯកសារដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20 របស់សហព្រះរាជអាជ្ញា និងឯកសារដែលបានស្នើឡើងដោយភាគីផ្សេងទៀត, កថាខណ្ឌ៩(ច) ដែលយោងឯកសារលេខ **E185** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើការជំទាស់ទៅនឹងឯកសារដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និងជំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសវនាការពីរដំណាក់កាលដំបូង នៃសំណុំរឿង ០០២/០១, ៩ មេសា ២០១២ ត្រង់កថាខណ្ឌ២៣។

11. ទាក់ទងនឹងឯកសារចំនួន៥២ ក្នុងឧបសម្ព័ន្ធ គ១ របស់ កសព ដែលមេធាវីការពារក្តីបានពិចារណាទាំងមានកំហុសថា ជាឯកសារស្ថិតនៅក្រៅវិសាលភាពសំណុំរឿង០០២/០២យ៉ាងជាក់ស្តែងនោះ តាមពិត គឺដូចតទៅ៖

(i) ឯកសារចំនួន២៦ ចុះកាលបរិច្ឆេទមុនថ្ងៃទី១៧ មេសា ១៩៧៥ គឺពាក់ព័ន្ធនឹងប្រវត្តិសាវតារ[21]។ ក្នុងចំណោមឯកសារទាំងនេះ មានឯកសារ៩ ពាក់ព័ន្ធនឹងសកម្មភាពរបស់ ខៀវ សំផន នៅមុនថ្ងៃទី១៧ មេសា ១៩៧៥ (ប្រវត្តិសាវតាររបស់ជនជាប់ចោទ តួនាទីក្នុងការបង្កើតឲ្យមានគោលនយោបាយនានា ព័ត៌មានអំពីចរិតលក្ខណៈ)[22]។ ឯកសារ៥ ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តិចំពោះពុទ្ធសាសនិកជននៅក្នុងតំបន់ "រំដោះ"[23] (ការចាប់បដិសន្ធិនៃគោលនយោបាយចំពោះពុទ្ធសាសនា ភ័ស្តុតាងបរិបទ)។ ឯកសារ១៤ ពាក់ព័ន្ធនឹងការកាប់សម្លាប់ ការជម្លៀសដោយបង្ខំ និងអំពើហិង្សាផ្សេងៗទៀត ដែលគេបានប្រើប្រាស់ប្រឆាំងប្រជាជនស៊ីវិល(ភ័ស្តុតាងបរិបទ ទ្រង់ទ្រាយនៃការប្រហារយ៉ាងទូលំទូលាយ ឬជាប្រព័ន្ធប្រឆាំងប្រជាជនស៊ីវិល)[24] និងឯកសារ១ ពាក់ព័ន្ធនឹងលក្ខខណ្ឌរស់នៅ និងការធ្វើការងារតាមសហករណ៍នានា(ការចាប់បដិសន្ធិនៃគោលនយោបាយសហករណ៍ និងការដ្ឋាន)[25]។

(ii) ឯកសារចំនួន៥ ពាក់ព័ន្ធប្រតិបត្តិការរបស់មន្ទីរសន្តិសុខ ម-១៣ នៅក្រោមសិទ្ធិអំណាចរបស់ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច[26]។ ឯកសារទាំងនេះ គឺពាក់ព័ន្ធទៅនឹងគោលនយោបាយចំពោះជនដែលគេចោទថាខ្មាំង នៅមុនថ្ងៃទី១៧ មេសា ១៩៧៥ និងប្រវត្តិមន្ទីរសន្តិសុខ

---

[21] ឯកសារទាំងនេះគឺ៖ **D313/1.2.26**, **E282.1.1**, **E282.1.2**, **E282.1.3**, **E282.1.4**, **E282.1.5**, **E282.1.6**, **E282.1.7**, **E282.1.8**, **E282.1.9**, **E282.1.10**, **E282.1.11**, **E282.1.12**, **E282.1.13**, **E282.1.14**, **E282.1.15**, **E282.1.16**, **E282.1.17**, **E282.1.18**, **E282.1.19**, **E282.1.20**, **E282.1.21**, **E282.1.22**, **E282.1.23**, **E282.1.24**, **E282.1.25**។ កថាខណ្ឌពាក់ព័ន្ធក្នុងឯកសារ **D427** ដីកាដំណោះស្រាយគឺ ១៨-៣២។

[22] **E282.1.9, E282.1.10, E282.1.12, E282.1.13, E282.1.14, E282.1.15, E282.1.16, E282.1.19, E282.1.22**។

[23] **D313/1.2.26, E282.1.2, E282.1.3, E282.1.17, E282.1.23**។

[24] **E282.1.1, E282.1.2, E282.1.3, E282.1.4, E282.1.5, E282.1.6, E282.1.7, E282.1.8, E282.1.11, E282.1.18, E282.1.20, E282.1.21, E282.1.24, E282.1.25**។ សូមកត់សម្គាល់ថា ឯកសារ **E282.1.2** & **E282.1.3** ជាប់ទាក់ទងទាំងអំពីការប្រព្រឹត្តិចំពោះពុទ្ធសាសនិកជន និងអំពើហិង្សាប្រឆាំងប្រជាជនស៊ីវិល។

[25] **E282.1.3**។ ឯកសារនេះក៏ពាក់ព័ន្ធនឹងការប្រព្រឹត្តិចំពោះពុទ្ធសាសនិកជន និងអំពើហិង្សាប្រឆាំងប្រជាជនស៊ីវិលដែរ។

[26] **IS1.4, IS19.25, D108/27.4, D108/27.12, D108/27.2**។ សូមមើល ដីកាដំណោះស្រាយ កថាខណ្ឌ១៨-៣២ និង ៤១៥-៤៧៥។

ជាទូទៅ និងជាពិសេស ការប្រព្រឹត្តទៅនៃ ស-២១ រួមទាំងការសួរចម្លើយ បច្ចេកទេសធ្វើទារុណកម្ម និងការសម្លាប់នៅក្រោមការគ្រប់គ្រងផ្ទាល់របស់បុគ្គលខាងលើគឺ ឌុច។

(iii) ឯកសារចំនួន២ ពាក់ព័ន្ធផ្ទាល់នឹងមន្ទីរសន្តិសុខស-២១ និងការបោសសម្អាតផ្ទៃក្នុង[27]។

(iv) ឯកសារចំនួន១៤ ពាក់ព័ន្ធនឹងការប្រព្រឹត្តិចំពោះក្រុមគោលដៅនានា[28] ក្នុងនោះរួមមានឯកសារ៣ ទាក់ទងនឹងការសម្លាប់មន្ត្រីរាជការនៃរបបសាធារណរដ្ឋខ្មែរ[29] និងឯកសារ១១ ទាក់ទងនឹងការប្រព្រឹត្តចំពោះពុទ្ធសាសនិកជន[30]។ ទោះបីឯកសារទាំងនោះ មិនពាក់ព័ន្ធផ្ទាល់ទៅនឹងទីតាំងឧក្រិដ្ឋកម្មជាក់លាក់ ដូចបានលើកឡើងក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលេខ E301/9/1.1 ក៏ដោយ[31] ក៏ឯកសារទាំងនោះនឹងមានប្រយោជន៍ជាភ័ស្តុតាងបរិបទ លាតត្រដាងពីទ្រង់ទ្រាយឧក្រិដ្ឋកម្មនៅទូទាំងប្រទេស និងបំពេញបាននូវ "លក្ខខណ្ឌគ្រប់ដណ្តប់រួមនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (ការវាយប្រហារទូលំទូលាយ ឬជាប្រព័ន្ធប្រឆាំងប្រជាជនស៊ីវិល)។

(v) ឯកសារសំខាន់ ២ ពាក់ព័ន្ធទៅនឹងការបោសសម្អាតផ្ទៃក្នុង (សម្អាងហេតុស្តីពីសហឧក្រិដ្ឋកម្មរួម មន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្ស ភ័ស្តុតាងផ្ទាល់ ភ័ស្តុតាងបរិបទ ឬភ័ស្តុតាងស្តីអំពីធាតុផ្សំ "ទូទៅ" នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)[32]។

---

[27] **D108/7.8, D108/40.7**: ដីកាដំណោះស្រាយ កថាខណ្ឌ១៧៨-២០៣ និង ៩១៥-៩៧៤។

[28] **E282.1.26, D366/7.1.592, IS19.66, D267/3.44, D267/3.43, D267/3.52, D267/3.68, D267/3.53, D267/3.58, E305/13.22.2, IS19.62, D267/3.75, D267/3.78, IS19.128**។ សូមមើល ដីកាដំណោះស្រាយ កថាខណ្ឌ២០៥-២០៧, ២១០, ៧៤០-៧៤៣ & ២០៥-២០៩, ១៣៥០-១៣៧២។

[29] **E282.1.26, D366/7.1.592, IS19.66**។

[30] **D267/3.44, D267/3.43, D267/3.52, D267/3.68, D267/3.53, D267/3.58, E305/13.22.2, IS19.62, D267/3.75, D267/3.78, IS19.128**។

[31] **E301/9/1.1** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីវិសាលភាពនៃសំណុំរឿង០០២/០២ - ឧបសម្ព័ន្ធ មានចំណងជើងថា "បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងការជំនុំជម្រះ សំណុំរឿងលេខ ០០២/០២", ត្រង់ ERN ជាភាសាអង់គ្លេស EN 00981688។

[32] ឯកសារ E127/7.1.15 & ឯកសារ E127/7.1.15R និងឯកសារ E127/7.1.15 & E127/7.1.15R។ ជនរងគ្រោះដោយសារការបោសសំអាតមួយចំនួនដែលបានពិពណ៌នានៅក្នុងឯកសារទាំងនោះ ត្រូវបានគេបញ្ជូន និងសម្លាប់នៅមន្ទីរ ស-២១។ សូមមើល ដីកាដំណោះស្រាយ កថាខណ្ឌពាក់ព័ន្ធ 178-203, 1350-1372។

(vi) ឯកសារ ៣ ពាក់ព័ន្ធជាសំខាន់ ប៉ុន្តែមិនមែនទាំងអស់ទេ ទៅនឹងសកម្មភាព ចម្លើយ និង/ឬ ការទទួលខុសត្រូវរបស់ជនជាប់ចោទ <u>ខៀវ សំផន</u> នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[33]។

## ខ. ឧបសម្ព័ន្ធ គ១៖ ឯកសារ ១៥ ដែលត្រូវបានចោទប្រកាន់ថា ស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០២ ឬបើមិនដូច្នេះទេ ជាឯកសារជាន់គ្នា

12. ពាក់ព័ន្ធនឹងឯកសារទាំង ១៥ ដែលមាននៅក្នុងឧបសម្ព័ន្ធ គ១ ដែលមេធាវីការពារក្តីបានសន្និដ្ឋាន ដោយមិនត្រឹមត្រូវថាស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០២ ឬបើមិនដូច្នេះទេ ជាឯកសារជាន់គ្នា៖

(i) ឯកសារ ៣ គឺជា<u>ចម្លើយរបស់សាក្សីដែល ក.ស.ព បានស្នើឡើង សម្រាប់សំណុំរឿង ០០២/០២</u>[34] រួមមានឯកសារ ១ ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងមន្ទីរសន្តិសុខក្រាំងតាចាន់ និងតួនាទីរបស់ នួន ជា (ប្រធានដឹកនាំកិច្ចប្រជុំនៅបុរីកីឡា)[35] ឯកសារមួយទៀតទាក់ទងទៅនឹងការប្រព្រឹត្តិចំពោះជនជាតិចាម តួនាទីរបស់ នួន ជា និងការបោសសម្អាតផ្ទៃក្នុង[36] ហើយឯកសារមួយទៀតពាក់ព័ន្ធនឹងមន្ទីរសន្តិសុខអូរកន្សែង និងការបោសសម្អាតផ្ទៃក្នុង[37]។ ដោយសារតែឯកសារទាំងនេះជាចម្លើយរបស់សាក្សីដែល ក.ស.ព បានស្នើឡើង ដូច្នេះ ឯកសារទាំងនេះមានភាពពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងសំណុំរឿង ០០២/០២។ ជាការចាំបាច់ ចម្លើយទាំងនេះត្រូវតែជាផ្នែកមួយនៃភ័ស្តុតាងដែលត្រូវដាក់ចំពោះមុខអង្គជំនុំជម្រះ បន្ទាប់ពីមានការបញ្ជាក់ពីអង្គជំនុំជម្រះថា សាក្សីដែលត្រូវបានស្នើឡើងទាំងនេះនឹងត្រូវបានជ្រើសរើសឲ្យមកផ្តល់សក្ខីកម្ម។

---

33 ឯកសារ D84/2.3 ឯកសារ D84/2.4 ឯកសារ D56-Doc.495 ((ឯកសារចុងក្រោយគេនេះពាក់ព័ន្ធផងដែរទៅនឹងមន្ទីរ ស-២១)។ សូមមើល ដីកាដំណោះស្រាយ កថាខណ្ឌ 1126-1162, 1164-1200, 1521-1560, 1598-1604។

34 ឯកសារ D22/406 & ឯកសារ D22/406a ឯកសារ D22/2577 ឯកសារ E127/5.1.4។

35 ឯកសារ D22/406 & ឯកសារ D22/406a: ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ 489-514, 862-993។

36 ឯកសារ D22/2577: ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ 178-203, 205-207, 211-212, 745-770, 776-789, 862-993។

37 ឯកសារ E127/5.1.4: ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ 178-203 & 589-623។

(ii) ចម្លើយ ៧ ទាក់ទងទៅនឹងការប្រព្រឹត្តិចំពោះក្រុមគោលដៅ[38] រួមមានចម្លើយ ៦ ដែលទាក់ទងទៅនឹងការប្រព្រឹត្តិចំពោះពុទ្ធសាសនិក (ភ័ស្តុតាងបរិបទ និងធាតុផ្សំ "ទូទៅ")[39] ហើយចម្លើយ ១ ទៀតពាក់ព័ន្ធនឹងការប្រព្រឹត្តិចំពោះជនជាតិចាម[40] (ភ័ស្តុតាងផ្ទាល់ និងភ័ស្តុតាងបរិបទ)។

(iii) ចម្លើយ ២ ពាក់ព័ន្ធទៅនឹងការបោសសម្អាតផ្ទៃក្នុងរបស់ បកក[41]។

(iv) ចម្លើយ ១ ទាក់ទងទៅនឹងមន្ទីរសន្តិសុខ ស-២១ តួនាទីរបស់ នួន ជា ជាប្រធានដឹកនាំមេទ្ទេញ និងការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង[42]។

(v) ចម្លើយ ១ ពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខ ស-២១ (ការធ្វើទារុណកម្មក្នុងពេលសួរចម្លើយ លក្ខខណ្ឌនៃការឃុំខ្លួន ការបោសសម្អាតផ្ទៃក្នុង)[43]។

(vi) ចម្លើយ ១ ពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធឃោធា ការបោសសម្អាតផ្ទៃក្នុងចំពោះកម្មាភិបាលជាន់ខ្ពស់នៃកងទ័ពបដិវត្តន៍កម្ពុជា រួមទាំងនៅមន្ទីរ ស-២១ និងការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង[44]។

### គ. ឧបសម្ព័ន្ធ គ២៖ ឯកសារ ៣២ ដែលត្រូវបានចោទប្រកាន់ថា ឥតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០២

13. ពាក់ព័ន្ធនឹងឯកសារទាំង ៣២ ដែលមាននៅក្នុងឧបសម្ព័ន្ធ គ២ របស់ ក.ស.ព ដែលមេធាវីការពារក្តីបានសន្និដ្ឋានដោយមិនត្រឹមត្រូវថាពិតជាស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០២ សហព្រះរាជអាជ្ញាផ្តល់ព័ត៌មានលម្អិត បន្ថែមទៅនឹងព័ត៌មានដែលមាននៅក្នុងតារាង E305/13.23៖

---

[38] ឯកសារ D315/8.60 ឯកសារ D267/3.41 ឯកសារ D267/3.47 ឯកសារ D267/3.51 ឯកសារ D267/3.60 ឯកសារ D267/3.76 ឯកសារ D175/3.44។ ដីកាដំណោះស្រាយ កថាខណ្ឌ 205-207, 210-212, 740-743, 745-770, 776-789)។

[39] ឯកសារ D315/8.60 (ពាក់ព័ន្ធផងដែរទៅនឹង មន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្ស និងការបោសសំអាតផ្ទៃក្នុង) ឯកសារ D267/3.41 (ផ្តល់ជូនផងដែរនូវព័ត៌មានលម្អិតស្តីអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ) ឯកសារ D267/3.47 ឯកសារ D267/3.51 ឯកសារ D267/3.60 ឯកសារ D267/3.76។

[40] ឯកសារ D175/3.44។

[41] ឯកសារ IS19.89 & ឯកសារ E127/5.1.30។ ដីកាដំណោះស្រាយ កថាខណ្ឌ 178-203។

[42] ឯកសារ IS19.143។

[43] ឯកសារ IS19.107។

[44] ឯកសារ E127/5.1.14: ដីកាដំណោះស្រាយ កថាខណ្ឌ 113-149, 178-203, 383-398។

(i) ឯកសារ ៩ គឺជាផែនទីសម័យអ៊ុនតាក់ ដែលបង្ហាញពីស្រុកពាក់ព័ន្ធផ្សេងៗនៅខេត្តកំពង់ចាម មណ្ឌលគិរី រតនគិរី បន្ទាយមានជ័យ កំពង់ធំ និងកំពង់ឆ្នាំង[45]។ ផែនទីទាំងនេះមានភាពពាក់ព័ន្ធ ដោយសារតែផែនទីទាំងនេះទាក់ទងដោយផ្ទាល់ទៅនឹងទាំងតំបន់ដែលជាទីតាំងនៃមន្ទីរសន្តិសុខដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង (ដូចជា មន្ទីរសន្តិសុខភ្នំក្រោល និងមន្ទីរសន្តិសុខអូរកន្សែង)[46] ស្រុកនៅខេត្តកំពង់ចាមដែលមានការចោទប្រកាន់ថាជាទីតាំងប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងជនជាតិចាម[47] ឬតំបន់ផ្សេងទៀតដែលទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋក្នុងសំណុំរឿង ០០២/០២៖ ទំនប់ត្រពាំងថ្ម[48] ទំនប់១មករា[49] និងការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង[50]។

(ii) មានរូបថត ខៀវ សំផន ចំនួន ៦ សន្លឹក ដែលបង្ហាញពីសកម្មភាពធ្វើដំណើររបស់គាត់ទៅប្រទេសឡាវក្នុងឆ្នាំ១៩៧៥[51]។ រូបថតទាំងនេះទាក់ទងទៅនឹងភារកិច្ចជាផ្លូវការរបស់ ខៀវ សំផន និងពាក់ព័ន្ធទៅនឹងតួនាទីរបស់ ខៀវ សំផន និងសាវតាររបស់គាត់។

(iii) ចម្លើយ ៧ ទាក់ទងទៅនឹងការបោសសម្អាតផ្ទៃក្នុង (ភស្តុតាងផ្ទាល់ ភស្តុតាងបរិបទ និងធាតុផ្សំ "ទូទៅ")[52]។

---

[45] ឯកសារ E305/13.23.37 ឯកសារ E305/13.23.39 ឯកសារ E305/13.23.40 ឯកសារ E305/13.23.41 ឯកសារ E305/13.23.42 ឯកសារ E305/13.23.43 ឯកសារ E305/13.23.44 ឯកសារ E305/13.23.45 ឯកសារ E305/13.23.46។

[46] ឯកសារ E305/13.23.39 ឯកសារ E305/13.23.41: ដីកាដំណោះស្រាយ កថាខណ្ឌ 589-642។

[47] ឯកសារ E305/13.23.37 ឯកសារ E305/13.23.42 ឯកសារ E305/13.23.43 ឯកសារ E305/13.23.44: ដីកាដំណោះស្រាយ កថាខណ្ឌ 205-207, 211-212, 745-770, 776-789។

[48] ឯកសារ E305/13.23.40: ដីកាដំណោះស្រាយ កថាខណ្ឌ 168-177, 323-349។

[49] ឯកសារ E305/13.23.45: ដីកាដំណោះស្រាយ កថាខណ្ឌ 168-177, 351-367។

[50] ឯកសារ E305/13.23.46: ដីកាដំណោះស្រាយ កថាខណ្ឌ 168-177, 383-398។

[51] ឯកសារ E305/13.23.53 ឯកសារ E305/13.23.54 ឯកសារ E305/13.23.55 ឯកសារ E305/13.23.56 ឯកសារ E305/13.23.57 ឯកសារ E305/13.23.58: ដីកាដំណោះស្រាយ កថាខណ្ឌ 18-32, 1126-1162, 1164-1200។

[52] ឯកសារ E305/13.23.310, ឯកសារ E305/13.23.322 (ពាក់ព័ន្ធផងដែរទៅនឹងការដាក់ បទបញ្ជាអំពីការ រៀបអាពាហ៍ពិពាហ៍) ឯកសារ E305/13.23.332 (ពាក់ព័ន្ធផងដែរទៅនឹង រចនាសម្ព័ន្ធយោធា និងរចនាសម្ព័ន្ធរដ្ឋបាល(មជ្ឈិម)) ឯកសារ E305/13.23.373 ឯកសារ E305/13.23.388 (ពាក់ព័ន្ធផងដែរទៅនឹង រចនាសម្ព័ន្ធយោធា និងរចនាសម្ព័ន្ធរដ្ឋបាល(មជ្ឈិម) និងគោលនយោបាយស្តីអំពីសហករណ៍ និងការដ្ឋាន) ឯកសារ E305/13.23.419 (ពាក់ព័ន្ធផងដែរទៅនឹង គោលនយោបាយស្តីអំពីសហករណ៍ និងការដ្ឋាន) ឯកសារ E305/13.23.435 (ពាក់ព័ន្ធផងដែរទៅនឹង រចនាសម្ព័ន្ធយោធា និងរចនាសម្ព័ន្ធរដ្ឋបាល(មជ្ឈិម))។

(iv) ចម្លើយ ៥ ពាក់ព័ន្ធទៅនឹងការស្វែងរក/ការសម្លាប់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ឬអ្នកដែលពាក់ព័ន្ធជាមួយពួកគេ[53]។

(v) ចម្លើយ ២ ទាក់ទងទៅនឹងការប្រព្រឹត្តិចំពោះពុទ្ធសាសនិក មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ (ភ័ស្តុតាងបរិបទ)[54]។

(vi) ចម្លើយ ១ របស់សាក្សីដែល ក.ស.ព បានស្នើឡើង ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តិចំពោះជនជាតិចាម[55] ចម្លើយ ១ ពណ៌នាអំពីការប្រព្រឹត្តិចំពោះពុទ្ធសាសនិក នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[56]។

(vii) ចម្លើយ ១ ពាក់ព័ន្ធទៅនឹងសំអាងហេតុនៃសហឧក្រិដ្ឋកម្មរួម មន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្ស[57]។

### ឃ. ឧបសម្ព័ន្ធ គ២- ឯកសារចំនួន ៤៤ ដែលត្រូវបានចោទប្រកាន់ថាភាគច្រើនស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០២ ឬបើមិនដូច្នេះទេ ជាឯកសារជាន់គ្នា

14. ទាក់ទិននឹងឯកសារចំនួន ៤៤ ដែលមាននៅក្នុងបញ្ជីឧបសម្ព័ន្ធ គ២ ដែលមេធាវីការពារក្តីយល់ឃើញថាភាគច្រើនស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០២ ឬបើមិនដូច្នេះទេ ជាឯកសារជាន់គ្នានោះ សហព្រះរាជអាជ្ញាកត់សម្គាល់ថា ឯកសារចំនួន ៣៨ ក្នុងចំណោមឯកសារទាំងនោះ គឺជាចម្លើយដែលមជ្ឈមណ្ឌលឯកសារកម្ពុជា ("DC-Cam") ប្រមូលចងក្រងបាន។ វាជាប្រការមិនត្រឹមត្រូវឡើយ សម្រាប់មេធាវីការពារក្តីក្នុងការស្នើថា ដោយសារតែ DC-Cam មិនមែនជាស្ថាប័នតុលាការ ដែលផ្តោតជាសំខាន់ទៅលើបញ្ហាសំណុំរឿង ០០២/០២ ភ័ស្តុតាងដែលប្រមូលបាននោះ ប្រាកដជាស្ថិតនៅក្រៅវិសាលនៃសំណុំរឿង០០២/០២។ ផ្ទុយទៅវិញ ផ្នែកដ៏ធំនៃចម្លើយ

---

[53] ឯកសារ E305/13.23.333 ឯកសារ E305/13.23.357 ឯកសារ E305/13.23.363 ឯកសារ E305/13.23.391 និង ឯកសារ E305/13.23.424: ដីកាដំណោះស្រាយ កថាខណ្ឌ 178-203, 205-209។

[54] ឯកសារ E305/13.23.288 ឯកសារ E305/13.23.298: ដីកាដំណោះស្រាយ កថាខណ្ឌ 18-32, 205-207 និង 210។ ឯកសារ E305/13.23.288 ពាក់ព័ន្ធផងដែរទៅនឹងការប្រព្រឹត្តលើជនជាតិវៀតណាម (ខ្មែរក្រោម) និងពាក់ព័ន្ធ ដោយផ្ទាល់ទៅនឹងតួនាទីរបស់ ខៀវ សំផន ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។

[55] ឯកសារ E305/13.23.421: ដីកាដំណោះស្រាយ កថាខណ្ឌ 205-207, 211-212, 745-770 & 776-789។

[56] ឯកសារ E305/13.23.428: ដីកាដំណោះស្រាយ កថាខណ្ឌ 205-207, 210 & 740-743។

[57] ឯកសារ E305/13.23.339: ដីកាដំណោះស្រាយ កថាខណ្ឌ 178-203។

ទាំងនោះដែលប្រមូលបានដោយ DC-Cam គឺតាមពិត ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការកត់សម្គាល់ ឃើញអំពីអង្គហេតុនៅក្នុងវិសាលភាពនៃការជំនុំជម្រះនេះ ដូច្នេះ គឺជាភ័ស្តុតាងដែលមានអានុភាព។ សហព្រះរាជអាជ្ញា ផ្ដល់នូវសេចក្ដីលម្អិត ទាក់ទិននឹងឯកសារចំនួន ៤៤ នោះ ដូចខាងក្រោមនេះ៖

(i) ឯកសារចំនួន ៦ ពាក់ព័ន្ធដោយផ្ទាល់ទៅនឹង មន្ទីរសន្តិសុខ ស-២១ (ដែលរួមមាន ព័ត៌មានស្ដីអំពីការដោះលែងអ្នកទោស)[58]។

(ii) សៀវភៅ/ការសិក្សាស្រាវជ្រាវចំនួន ២ ពាក់ព័ន្ធដោយផ្ទាល់ចំពោះការដាក់បទបញ្ជាអំពីការរៀបអាពាហ៍ពិពាហ៍[59] ដែលរួមមាន អំពីហិង្សាលើផ្លូវភេទប្រឆាំងនឹងជនជាតិវៀតណាម ខ្មែរក្រោម និងជនជាតិចាម។ ចម្លើយចំនួន ៤ទៀត ពាក់ព័ន្ធទៅនឹងការអនុវត្តការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[60]។

(iii) ចម្លើយចំនួន ៣ ពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទ នួន ជា និង/ឬ ខៀវ សំផន នៅក្នុងកិច្ចប្រជុំនានារបស់បក្សនៅក្នុងទីក្រុងភ្នំពេញ ឬតួនាទីរបស់ ខៀវ សំផន នៅក្នុងផ្នែកពាណិជ្ជកម្ម ព្រមទាំងពាក់ព័ន្ធទៅនឹងការបោសសំអាតផ្ទៃក្នុងរបស់បក្សកុម្មុយនីស្តកម្ពុជា[61]។ ចម្លើយចំនួន ១ ផ្សេងទៀត ពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទទាំងពីរ សារតារប្រវត្តិសាស្ត្រ និងរចនាសម្ព័ន្ធរដ្ឋបាល[62]។

---

58 ឯកសារ E305/13.23.1 ឯកសារ E305/13.23.68 ឯកសារ E305/13.23.304 ឯកសារ E305/13.23.381 ឯកសារ E305/13.23.418 ឯកសារ E305/13.23.436 (ពាក់ព័ន្ធផងដែរទៅនឹង ការប្រព្រឹត្តិចំពោះជនជាតិចាម): ដីកាដំណោះស្រាយ កថាខណ្ឌ 178-203, 415-474។

59 ឯកសារ E305/13.23.8 ឯកសារ E305/13.23.9: ដីកាដំណោះស្រាយ កថាខណ្ឌ 216-220, 842-860។

60 ឯកសារ E305/13.23.341 (ពាក់ព័ន្ធផងដែរទៅនឹងការប្រព្រឹត្តលើពុទ្ធសាសនិក) ឯកសារ E305/13.23.364 (ពាក់ព័ន្ធផងដែរទៅនឹងការបោសសំអាតផ្ទៃក្នុងរបស់បក្សកុម្មុយនីស្តកម្ពុជា) ឯកសារ E305/13.23.402 ឯកសារ E305/13.23.442 (ពាក់ព័ន្ធផងដែរទៅនឹងការប្រព្រឹត្តលើអតីតអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ)។

61 ឯកសារ E305/13.23.289 ឯកសារ E305/13.23.377 (ពាក់ព័ន្ធផងដែរទៅនឹងការប្រព្រឹត្តលើពុទ្ធសាសនិក ការប្រព្រឹត្តលើជនជាតិវៀតណាម) ឯកសារ E305/13.23.343 (ពាក់ព័ន្ធផងដែរទៅនឹងការប្រព្រឹត្តលើពុទ្ធសាសនិក នៅពេលដែលសាក្សី ខៀវ នៅ ត្រូវបានផ្សឹក តាមបញ្ជារបស់ តាម៉ុក)។ ឯកសារ E305/13.23.377 គឺជាចម្លើយរបស់សាក្សីម្នាក់ដែល ក.ស.ព បានស្នើឡើងសម្រាប់សវនាការ សំណុំរឿង ០០២/០២។

62 ឯកសារ E305/13.23.420។

(iv) ចម្លើយចំនួន ១១ ពាក់ព័ន្ធទៅនឹងការបោសសំអាតផ្ទៃក្នុងរបស់បក្សកុម្មុយនីស្តកម្ពុជា[63]។

(v) ចម្លើយចំនួន ១៥ ពាក់ព័ន្ធទៅនឹងការដ្ឋាន និងសហករណ៍នានា[64] ដែលរួមមាន ចម្លើយចំនួន ១៣ ស្តីអំពីទំនប់ត្រពាំងថ្ម[65] ចម្លើយចំនួន ១ ស្តីអំពី ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង[66] និងចម្លើយចំនួន ១ ស្តីអំពី សហករណ៍ត្រាំកក់[67]។

(vi) ចម្លើយចំនួន ១ ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តិចំពោះជនជាតិវៀតណាម[68] និង

(vii) ចម្លើយចំនួន ១ ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តិចំពោះអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[69]។

---

[63] ឯកសារ E305/13.23.290 ឯកសារ E305/13.23.300 ឯកសារ E305/13.23.321 ឯកសារ E305/13.23.325 ឯកសារ E305/13.23.389 ឯកសារ E305/13.23.399 ឯកសារ E305/13.23.410 (ពាក់ព័ន្ធផងដែរទៅនឹងជម្លោះប្រដាប់អាវុធ និងរចនាសម្ព័ន្ធយោធា) ឯកសារ E305/13.23.422 (ពាក់ព័ន្ធផងដែរទៅនឹង សាវតាររបស់ ខៀវ សំផន និងមន្ទីរសន្តិសុខ) ឯកសារ E305/13.23.434 ឯកសារ E305/13.23.452 (ពាក់ព័ន្ធផងដែរទៅនឹង តួនាទីរបស់ នួន ជា) ឯកសារ E305/13.23.470 (ពាក់ព័ន្ធផងដែរទៅនឹងតួនាទីរបស់ នួន ជា )។

[64] ឯកសារ E305/13.23.309 ឯកសារ E305/13.23.327 ឯកសារ E305/13.23.329 ឯកសារ E305/13.23.330 ឯកសារ E305/13.23.331 ឯកសារ E305/13.23.338 ឯកសារ E305/13.23.376 ឯកសារ E305/13.23.380 ឯកសារ E305/13.23.398 ឯកសារ E305/13.23.401 (ពាក់ព័ន្ធផងដែរទៅនឹងការប្រព្រឹត្តលើពុទ្ធសាសនិក និងការដាក់បញ្ហាអំពីការរៀបអាពាហ៍ពិពាហ៍) ឯកសារ E305/13.23.413 (ពាក់ព័ន្ធផងដែរទៅនឹងការប្រព្រឹត្តលើពុទ្ធសាសនិក) ឯកសារ E305/13.23.414 (ពាក់ព័ន្ធផងដែរទៅនឹងការប្រព្រឹត្តលើពុទ្ធសាសនិក និងការបោសសំអាតផ្ទៃក្នុង) ឯកសារ E305/13.23.430 ឯកសារ E305/13.23.447 (ពាក់ព័ន្ធផងដែរទៅនឹងការបោសសំអាតផ្ទៃក្នុង) ឯកសារ E305/13.23.471 (ពាក់ព័ន្ធផងដែរទៅនឹងការបោសសំអាតផ្ទៃក្នុង)។ កត់សម្គាល់ថា ឯកសារ E305/13.23.330 ឯកសារ E305/13.23.331 គឺជាចម្លើយរបស់សាក្សីបម្រុងដែល ក.ស.ព បានស្នើឡើងសម្រាប់សវនាការ សំណុំរឿង ០០២/០២។

[65] ឯកសារ E305/13.23.309 ឯកសារ E305/13.23.327 ឯកសារ E305/13.23.329 ឯកសារ E305/13.23.330 ឯកសារ E305/13.23.331 ឯកសារ E305/13.23.338 ឯកសារ E305/13.23.376 ឯកសារ E305/13.23.380 ឯកសារ E305/13.23.401 ឯកសារ E305/13.23.413 ឯកសារ E305/13.23.414 ឯកសារ E305/13.23.447 ឯកសារ E305/13.23.471។

[66] ឯកសារ E305/13.23.430។

[67] ឯកសារ E305/13.23.398។ ចម្លើយនេះ ពាក់ព័ន្ធផងដែរទៅនឹងមន្ទីរសន្តិសុខ ស-២១។

[68] ឯកសារ E305/13.23.407។

[69] ឯកសារ E305/13.23.454។

15. ដូចមូលដ្ឋានខាងលើនេះ ភស្តុតាងដែលបានផ្តល់ជូននៅក្នុងឧបសម្ពន្ធ គ១ និង គ២ គឺ*តាមការវិភាគបឋម* មានសារៈសំខាន់យ៉ាងខ្លាំងចំពោះបញ្ហានានា ដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ (អត្ថិភាពនៃសូចនាករអំពីភាពជាប់ពាក់ព័ន្ធ)។

## III. សេចក្តីសន្និដ្ឋាន

16. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាសូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង៖

ក. បដិសេធសារណារបស់មេធាវីការពារក្តីដែលថា ឧបសម្ព័ន្ធ ឃ១, ឃ២ និង ឃ៣ ដែលភ្ជាប់ជាមួយនឹងសំណើរបស់សហព្រះរាជអាជ្ញា ឯកសារ E305/13/1 ចុះកាលបរិច្ឆេទថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០១៤ ត្រូវស្ថិតនៅក្រោមលក្ខខណ្ឌតម្រូវនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង

ខ. បដិសេធការជំទាស់ដែលមេធាវីការពារក្តី ខៀវ សំផន បានលើកឡើងនៅក្នុងតារាងឯកសារ E327/3.2 ទាក់ទិននឹងឯកសារចំនួន ១៤៣ ដែលមាននៅក្នុងបញ្ជីឧបសម្ព័ន្ធ គ១ និង គ២ របស់សហព្រះរាជអាជ្ញា និង

គ. អនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ទទួលយកជាភស្តុតាង នូវរាល់ឯកសារទាំងអស់ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤ នៅ ក្នុងឧបសម្ព័ន្ធ ១ក ដល់ ២០ក និងឧបសម្ព័ន្ធ គ១ និង គ២ ដែលបានធ្វើបច្ចុប្បន្នភាព (ឯកសារ E305/13) ព្រមទាំងឯកសារទាំងអស់ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា នៅថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០១៤ នៅក្នុងឧបសម្ព័ន្ធ D1, D2 និង D3 (ឯកសារ E305/13/1)។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញា | | [signature] |